ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**

**សាលក្រមរដ្ឋប្បវេណី** **បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤**

លេខ: ១៤២ "ឃ"

**សាលក្រមប្រកាសជាសាធារណៈ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤។**

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤

សំណុំរឿងរដ្ឋប្បវេណីលេខ: ៥៨

ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ។

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ។

**រវាង** ដើមចោទឈ្មោះ [redacted] **សុភី** ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើកម្មកររោងចក្រ មានទី [redacted]។ ឪពុកឈ្មោះ [redacted] សឿន"រ" ម្តាយឈ្មោះ [redacted] ទូច"រ" ប្តីឈ្មោះ [redacted] សុវណ្ណរិទ្ធ"រ" មានកូនចំនួន ០២នាក់។ ដោយមានតំណាងដោយអាណត្តិលោកមេធាវី [redacted] និងលោកមេធាវី [redacted]។

**និង** ចុងចម្លើយឈ្មោះ [redacted] **សុវណ្ណរិទ្ធ** ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរបើកឡាន មានទីលំនៅសព្វថ្ងៃនៅ [redacted]។ ឪពុកឈ្មោះ [redacted] ពៅ"រ" ម្តាយឈ្មោះជ័យ សុផល"រ" ប្រពន្ធឈ្មោះ [redacted] សុភី"រ" មានកូនចំនួន ០២នាក់។

**<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:</u>** ប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេច នូវ:

១-លែងលះពីចុងចម្លើយឈ្មោះ [redacted] សុវណ្ណរិទ្ធ។

២-ជាអ្នកមានអំណាចមេបាលើកូនពីរនាក់ឈ្មោះ [redacted] ភក្តណា ភេទប្រុស ភេទប្រុស កើតថ្ងៃទី [redacted] និងកូនឈ្មោះ [redacted] សក្កណា ភេទស្រី កើតថ្ងៃទី [redacted]

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

### ១-<u>អង្គហេតុ</u>

-ក្នុងរឿងក្តីនេះ ដើមចោទឈ្មោះ [redacted] សុភី ភេទស្រី អាយុ ៣២ឆ្នាំ និងចុងចម្លើយឈ្មោះ [redacted] សុវណ្ណរិទ្ធ ភេទប្រុស អាយុ ៣៣ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃមិនចាំ ខែឧសភា ឆ្នាំ២០១១ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៤០ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់ឃុំវាលពង់។ ក្រោយពីបានរៀបការរួចមកការរស់នៅជាប្តីប្រពន្ធរបស់គូភាគីមានភាពមិនចុះសម្រុងគ្នា ជាហេតុបណ្តាលឲ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធ។ ម្យ៉ាងទៀតការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ គឺគូភាគីបានបង្កើតកូនពីរនាក់ឈ្មោះ [redacted] ភក័ណា ភេទប្រុស កើតថ្ងៃទី [redacted] និងកូនឈ្មោះ [redacted] សក្កណា ភេទស្រី កើតថ្ងៃទី [redacted]។ ចំពោះទ្រព្យរួម ទ្រព្យដោយឡែក និងបំណុលរួម គឺគ្មានទេ។

### ២-<u>សេចក្តីថ្លែងការណ៍របស់គូភាគី</u>

**ក**-ដើមចោទឈ្មោះ [redacted] **សុភី** បានថ្លែងការណ៍អំពីលទ្ធផល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះកែវ សុវណ្ណរិទ្ធ នៅថ្ងៃមិនចាំ ខែឧសភា ឆ្នាំ២០១១ ដោយបានចុះ



Scanned with CamScanner

សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ មូលហេតុដែលខ្លួនប្ដឹងសុំលែងលះពីប្ដីឈ្មោះ [redacted] សុវណ្ណរិទ្ធ ដោយសារការរស់នៅមិនចុះសម្រុងគ្នាបណ្ដាលឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀត។ ការរស់នៅជាប្ដីប្រពន្ធ គឺមានកូនពីរនាក់ឈ្មោះ [redacted] ភក្ដណា ភេទប្រុស ភេទប្រុស កើតថ្ងៃទី [redacted] និងកូនឈ្មោះ [redacted] សក្ដណា ភេទស្រី កើតថ្ងៃទី [redacted] ដោយខ្លួនសុំជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់ និងមិនប្ដឹងទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនទាំងពីរនាក់នោះទេ។ រីឯទ្រព្យរួម ទ្រព្យដោយឡែក និងបំណុលរួម គឺគ្មានទេ។ ចំពោះប្រាក់ប្រដាប់ក្ដី គឺខ្លួនសុខចិត្តទទួលបន្ទុក។

**សំណូមពរ:** សុំឱ្យតុលាការចេញសាលក្រមសម្រេច៖

១-លែងលះពីចុងចម្លើយឈ្មោះ [redacted] សុវណ្ណរិទ្ធ។

២-ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ភក្ដណា និងកូនឈ្មោះ [redacted] សក្ដណា។

**ខ-**ចុងចម្លើយឈ្មោះ [redacted] **សុវណ្ណរិទ្ធ** បានថ្លែងការណ៍អំពីលទ្ធផល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួន និងឈ្មោះ [redacted] សុភី ពិតជាបានរៀបអាពាហ៍ពិពាហ៍ កាលពីថ្ងៃមិនចាំ ខែឧសភា ឆ្នាំ២០១១ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ ខ្លួនមិនឯកភាពលែងលះជាមួយឈ្មោះ [redacted] សុភី ដោយសារខ្លួននៅស្រឡាញ់ប្រពន្ធ។ ការរស់នៅជាប្ដីប្រពន្ធ គឺមានកូនពីរនាក់ឈ្មោះ [redacted] ភក្ដណា ភេទប្រុស ភេទប្រុស កើតថ្ងៃទី [redacted] និងកូនឈ្មោះ [redacted] សក្ដណា ភេទស្រី កើតថ្ងៃទី [redacted] ដោយខ្លួនយល់ព្រមឱ្យដើមចោទឈ្មោះ [redacted] សុភី ជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់តាមការប្ដឹងទាមទារ។ រីឯ ទ្រព្យរួម ទ្រព្យដោយឡែក និងបំណុលរួម គឺគ្មានទេ។

**សំណូមពរ៖** សុំឱ្យតុលាការចេញសាលក្រមសម្រេចឱ្យឈ្មោះ [redacted] សុភី ជាអ្នកមានអំណាចមេបាលើកូនពីរនាក់ឈ្មោះ [redacted] ភក្ដណា និងកូនឈ្មោះ [redacted] សក្ដណា។

**គ-**មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទលោកមេធាវី [redacted] បានថ្លែងការណ៍បញ្ជាក់ថា: ដើមចោទឈ្មោះ [redacted] សុភី បានប្ដឹងលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] សុវណ្ណរិទ្ធ។ ប៉ុន្តែចុងចម្លើយមិនព្រមឯកភាពលែងលះនោះទេ។ ចំណែកឯការកំណត់អំណាចមេបាលើកូនទាំងពីរនាក់នោះ គឺចុងចម្លើយបានយល់ព្រមឱ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់តាមការប្ដឹងទាមទារ។ ដូច្នេះសុំឱ្យតុលាការសម្រេចឱ្យកូនក្ដីរបស់ខ្លួនលែងលះពីចុងចម្លើយ និងជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់។

**ឃ-**មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទលោកមេធាវី [redacted] បានថ្លែងការណ៍បញ្ជាក់ថា: ដោយសារតែកូនក្ដីរបស់ខ្លួនមានការរស់នៅជាប្ដីប្រពន្ធមិនចុះសម្រុងជាមួយចុងចម្លើយឈ្មោះ [redacted] សុវណ្ណរិទ្ធ ទើបកូនក្ដីរបស់ខ្លួនសុំលែងលះ។ ខ្លួនឯកភាពយល់ស្របតាមការថ្លែងការណ៍របស់លោកមេធាវី [redacted] ទាំងស្រុង។

**៣-<u>ចំណុចវិវាទ:</u>** តើការប្ដឹងលែងលះរបស់ដើមចោទឈ្មោះ [redacted] សុភី ជាមួយចុងចម្លើយឈ្មោះ [redacted] សុវណ្ណរិទ្ធ មានមូលហេតុត្រឹមត្រូវ ឬទេ?

## <u>ការសំអាងហេតុ</u>

១-ដើមចោទ និងចុងចម្លើយ ពិតជាសហព័ទ្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានចម្លើយរបស់គូភាគី និងសំបុត្រអាពាហ៍ពិពាហ៍លេខ៤០ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់ឃុំវាលពង់ ជាភស្តុតាងស្រាប់។

២-ដើមចោទបានប្ដឹងសុំលែងលះពីចុងចម្លើយដោយសំអាងថា: ខ្លួន និងចុងចម្លើយមានការរស់នៅមិនចុះសម្រុងគ្នាហើយ ជាហេតុបណ្ដាលឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀត។ រីឯ ចុងចម្លើយ



Scanned with CamScanner

មិនឯកភាពក្នុងការលែងលះតាមការប្តឹងទាមទាររបស់ដើមចោទនោះទេ។ ដូច្នេះស្ថានភាពរបស់គូភាគីក្នុងការរស់នៅជាប្តីប្រពន្ធ គឺមិនអាចរក្សាទំនាក់ទំនងអាពាហ៍ពិពាហ៍ និងមានស្ថានភាពធ្ងន់ធ្ងរដែលគ្មានសង្ឃឹមថានឹងអាចស្តារឡើងវិញបាន។ ហេតុនេះ ការប្តឹងសុំលែងលះរបស់ដើមចោទ គឺមានមូលហេតុត្រឹមត្រូវតាមមាត្រា៩៧៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៣-គូភាគីបានថ្លែងការណ៍ថា: ការរស់នៅជាប្តីប្រពន្ធបង្កើតបានកូនពីរនាក់ គឺឈ្មោះ[redacted] ភក្ក័ណា ភេទប្រុស កើតថ្ងៃទី [redacted]និងកូនឈ្មោះ[redacted] សក្កណា ភេទស្រី កើតថ្ងៃទី[redacted]ដោយដើមចោទប្តឹងទាមទារជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់ ដោយមិនប្តឹងទាមទារសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនពីចុងចម្លើយនោះទេ។ រីឯ ចុងចម្លើយយល់ព្រមប្រគល់អំណាចមេបាលើកូនទាំងពីរនាក់ឲ្យដើមចោទតាមការប្តឹងទាមទារ។ ដូច្នេះ ការថ្លែងការណ៍នេះមានភាពស៊ីសង្វាក់ជាមួយសំបុត្រកំណើតលេខ២៨ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឃុំវាលពង់ និងសំបុត្រកំណើតលេខ៥៤ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ឃុំវាលពង់ បញ្ជាក់ថា: ឈ្មោះ[redacted] ភក្ក័ណា ភេទប្រុស កើតថ្ងៃទី[redacted]និងកូនឈ្មោះ[redacted] សក្កណា ភេទស្រី កើតថ្ងៃទី[redacted] ពិតជាកូនរបស់គូភាគីប្រាកដមែន។ គប្បី តុលាការសម្រេចការកំណត់យកអ្នកមានអំណាចមេបាលើកូនតាមការព្រមព្រៀង និងមិនពិចារណាលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូននោះទេ។

៤-គូភាគីបានថ្លែងការណ៍ថា: ចំពោះទ្រព្យរួម ទ្រព្យដោយឡែក និងបំណុលរួម គឺគ្មានទេ។

៥-ប្រាក់ប្រដាប់ក្តី គឺដើមចោទសុខចិត្តទទួលបន្ទុក។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឲ្យឈ្មោះ[redacted] សុវណ្ណរិទ្ធ និងនាងឈ្មោះ[redacted] សុគី លែងលះជាប្តីប្រពន្ធ។

តាមមាត្រា៩៧៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

២-កំណត់យកឈ្មោះ[redacted] សុគី ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ[redacted] ភក្ក័ណា ភេទប្រុស កើតថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ និងកូនឈ្មោះ[redacted] សក្កណា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

ចុងចម្លើយដែលពុំមានអំណាចមេបាមានសិទ្ធិចួលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ រីឯ ដើមចោទដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ចុងចម្លើយ។

តាមមាត្រា១០៣៧ និងមាត្រា១០៤០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ[redacted] សុគី។៸.

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

កំពង់ស្ពឺ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner